# សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**
# ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់
# គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

២៧ មិនា ២០១៣

**សូមគោរព ឯកឧត្តម ធៀង វុធ អភិបាលរងខេត្តប៉ៃលិន!**
**សូមគោរព លោកបណ្ឌិត ទូច វិសាលសុខ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបាត់ដំបង!**
**សូមគោរព លោក ស៊ុន ម៉ៅ ទីប្រឹក្សាបច្ចេកទេសនៃអង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (ស៊ី.អ.ឌី.ធី)!**
**សូមគោរព លោកស្រី សោ មុនីរ័ត្ន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន!**
**សូមគោរព លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយចំនួន៤ ក្នុងថ្ងៃនេះសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរដែលកិច្ចសន្យាផ្តល់ជំនួយទាំងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៣ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងទាំង៤ ដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅជួយសម្រួលដល់ វិស័យកសិកម្ម និងកែលម្អការគ្រប់គ្រងទឹកជំនន់នៅតំបន់ជនបទ។ វិស័យកសិកម្ម និង ការគ្រប់គ្រងទឹកជំនន់មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅកម្ពុជាដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ទៅលើវិស័យទាំងនេះសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន។

ប្រទេសជប៉ុនបាន និងកំពុងបន្តជួយដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពី ឆ្នាំ១៩៩២មក ដោយសម្របគោលនយោបាយនៃជំនួយឧបត្ថម្ភរបស់ខ្លួនឲ្យស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជា។ គម្រោងទាំងនេះអនុទ្បោមទៅតាមគោលនយោបាយនៃជំនួយឧបត្ថម្ភរបស់ជប៉ុនចំពោះកម្ពុជា និងត្រូវទៅតាមគោលការណ៍នៃគម្រោងជំនួយខ្នាតតូចដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ជំនួយទី១មានថវិកាសរុប ១១៨,៩៩៦ ដុល្លាអាមេរិក ផ្តល់ជូនសាកលវិទ្យាល័យបាត់ដំបងសម្រាប់ការបំពាក់ធុងចំហុយសម្លាប់មេរោគពីរដែលមានទំហំ៥០ និង១៥០លីត្រ តុធ្វើការអនាម័យមួយ និងសាងសង់មន្ទីរពិសោធន៍ផ្ទះបៃតងចំនួនពីរដែលមានទំហំ៣០០ម៉ែត្រក្រឡា និង៦០០ម៉ែត្រក្រឡានៅក្នុងកសិដ្ឋានរបស់សាកលវិទ្យាល័យបាត់ដំបងដើម្បីបណ្តុះពូជដំឡូងមីដែលគ្មានមេរោគ។ យើងរំពឹងថាគម្រោងនេះនឹងកែលម្អផលិតភាពនៃការដាំដុះដំឡូងមី ក៏ដូចជាបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករប្រមាណ១,១៥០នាក់ក្នុងសហគមន៍ជនបទ។

ជំនួយទី២មានថវិកាសរុប៩១,១២១ដុល្លាអាមេរិកផ្តល់ជូនអង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាសម្រាប់សាងសង់ប្រព័ន្ធបន្សុទ្ធទឹកខ្នាតតូច និងដាក់បណ្តាញបំពង់ចែកចាយទឹកចំនួន ៣,០០០ម៉ែត្រក្នុងភូមិកោះផ្តៅ សាងសង់ប្រព័ន្ធចែកចាយទឹកសម្រាប់ធ្វើកសិកម្មដែលរួមមានអាងស្តុកទឹកចំណុះ៥,០០០លីត្រចំនួនពីរ និងប្រឡាយប្រវែង១,២០០ម៉ែត្រក្នុងភូមិសំភិន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។ យើងរំពឹងថាគម្រោងនេះនឹងអាចឲ្យកសិករ និង ប្រជាជនក្នុងតំបន់ជាង ២,០០០ នាក់អាចទទួលទានទឹកស្អាតមានសុវត្ថិភាព ក៏ដូចជាប្រើប្រាស់ទឹកពីទន្លេមេគង្គដើម្បីធ្វើកសិកម្ម។

ជំនួយទី៣មានថវិកាសរុប ៩៩,៨០០ដុល្លាអាមេរិក ផ្តល់ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិនសម្រាប់សាងសង់លូ១៤កន្លែង និងផ្លូវបង្ហៀរទឹក៣កន្លែងតាមបណ្តោយផ្លូវកសិកម្មក្នុងសង្កាត់អូរតាវ៉ៅ ខេត្តប៉ៃលិន។ យើងរំពឹងថាគម្រោងនេះនឹងកែលម្អស្ថានភាពទឹកជំនន់ ព្រមទាំងសម្រួលដល់ការធ្វើដំណើររបស់ប្រជាជនជាង៣,០០០នាក់ដែលរស់នៅក្នុងភូមិចំនួន៥ដែលនៅក្បែរនោះ។ យើងក៏សង្ឃឹមផងដែរថា គម្រោងនេះនឹងជួយលើកស្ទួយសេដ្ឋកិច្ចនៅក្នុងតំបន់តាមរយៈការជំរុញវិស័យពាណិជ្ជកម្ម។

ជំនួយទី៤មានថវិកាសរុប ១០៥,៤២២ដុល្លាអាមេរិកផ្តល់ជូនមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារសម្រាប់ការកែលម្អប្រព័ន្ធលូរំដោះទឹកប្រវែង៩០០ម៉ែត្រដែលមានប្រអប់លូចំនួន៣៦ក្នុងសង្កាត់កំពង់ប្រណាក ទីរួមខេត្តព្រះវិហារ។ យើងរំពឹងថាគម្រោងនេះនឹងកែលម្អស្ថានភាពទឹកជំនន់ ព្រមទាំងផ្តល់បរិស្ថានស្អាត និងមានសុវត្ថិភាពដល់ប្រជាជនប្រមាណ១០,០០០នាក់។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូននិងថែទាំយ៉ាងត្រឹមត្រូវដើម្បីឲ្យប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ចុងក្រោយនេះ ខ្ញុំក៏សង្ឃឹមផងដែរថា កិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!